# ព្រឹត្តិបត្រព័ត៌មាន

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

គ.ជ.ប NEC BULLETIN

លេខ ៦ ចេញផ្សាយថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣

Issue 6 : 5 / 7 / 2023


# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

## ការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ចាប់ផ្ដើមពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣

នាព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានបើកកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ នឹងការបោះឆ្នោត





ឯកឧត្តម ហ៊ីង ធីឫទ្ធិ សមាជិក គ.ជ.ប

ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** សមាជិក គ.ជ.ប និងជា

តទៅទំព័រទី២

**មាតិកា៖** **ទំព័រ**


- ការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ចាប់ផ្ដើមពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ....១
- អ្នកសង្កេតការណ៍ដែលត្រូវសង្កេតមើលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ .........៤
- តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោត ....................១០
- អ.ខ គំរូថ្មី ដែលអស់សុពលភាពប្រើប្រាស់ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ អាចប្រើប្រាស់បានសម្រាប់ការបោះឆ្នោត ....១១
- បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ...............១១
- ប្រធាន គ.ជ.ប អំពាវនាវឱ្យប្រជាពលរដ្ឋត្រៀមខ្លួន និងត្រៀមឯកសារ សម្រាប់ការបោះឆ្នោត ................................១៤
- សេចក្ដីអំពាវនាវ ស្ដីពីការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ...........................១៥

តមកពីទំព័រទី១ **ការស្នើសុំឯកសារ ...**

ប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតតាមឃុំ សង្កាត់ និងការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប)។

ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** បានមានប្រសាសន៍ថា អនុលោមតាមមាត្រា ១៦៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែពុំមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដើម្បីបោះឆ្នោត ប្រជាពលរដ្ឋនោះអាចប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត។ អាជ្ញាធរឃុំ សង្កាត់ និង គឃ.សប ត្រូវបានអនុញ្ញាតឱ្យចេញ



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) តាមការស្នើសុំជូនប្រជាពលរដ្ឋ ស្របតាមសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប លេខ ០៣៤ ស.ណ.ន ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១។ ឯកឧត្តមបានមានប្រសាសន៍បន្តទៀតថា យោងតាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ កាលបរិច្ឆេទសម្រាប់ការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតតាមឃុំ សង្កាត់ មានរយៈពេល ៣០ថ្ងៃ គឺចាប់ផ្តើមពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ត្រឹមម៉ោង ៥:៣០នាទីល្ងាច។

ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** បានបញ្ជាក់ជូនទៀតថា ដើម្បីស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត អ្នកបោះឆ្នោតត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖



**គណៈអធិបតីក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ**

- ត្រូវស្នើសុំក្នុងអំឡុងកាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើ
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ គឃ.សប នៃឃុំ សង្កាត់ដែលសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងត្រូវបោះឆ្នោត
- ត្រូវបំពេញពាក្យស្នើសុំ និងត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខប្រធាន គឃ.សប
- ត្រូវផ្តល់ស្នាមម្រាមដៃតាមការណែនាំរបស់សមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាល និងថតរូបសម្រាប់ការផ្ទៀងផ្ទាត់ និងទាញទិន្នន័យពីបញ្ជីបោះ-ឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។

ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** បានបញ្ជាក់ជូនបន្តទៀតថា បន្ទាប់ពីបានទទួល និងពិនិត្យលើពាក្យស្នើសុំ ប្រធាន គឃ.សប ត្រូវចេញ ឯ.អ ជូនអ្នកបោះឆ្នោត ដោយមិនតម្រូវឱ្យបង់ប្រាក់ឡើយ។ បន្ទាប់មកអ្នកបោះឆ្នោតត្រូវយក ឯ.អ ដែលចេញដោយ



**តំណាងភាគីពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំ**

ប្រធាន គឃ.សប ទៅកាន់សាលាឃុំ សង្កាត់ ដើម្បីឱ្យមេឃុំ ចៅសង្កាត់ ពិនិត្យ និងសម្រេចផ្ដល់សុពលភាពសម្រាប់ប្រើប្រាស់ជាផ្លូវការ។ អ្នកបោះឆ្នោតត្រូវរក្សាទុក ឯ.អ នោះ សម្រាប់យកទៅបង្ហាញដល់មន្ត្រីគណៈកម្មការការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត ទើបអាចបោះឆ្នោតបាន។

ពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតនៅ គឃ.សប ឯកឧត្តម **ហ៊ីង ធីឫទ្ធិ** បានជម្រាបជូនថា អនុលោមតាមមាត្រា ៤៣ និងមាត្រា ៩៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប ត្រូវបោះពុម្ពផ្សាយ និងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីស្នាក់ការ គឃ.សប ក្នុងរយៈ-



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

ពេលយ៉ាងតិច ៣០ ថ្ងៃ មុនថ្ងៃបោះឆ្នោត។ តាមប្រតិទិន ការបិទ-ផ្សាយនេះនឹងត្រូវធ្វើនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣។ ឯកឧត្តមបានជម្រាបជូនទៀតថា បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ត្រូវបានថតចម្លង និងផ្ញើជូន គឃ.សប ចំនួន ២ ច្បាប់ ដោយ ១ ច្បាប់ ត្រូវបិទផ្សាយនៅទីស្នាក់ការ គឃ.សប នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ហើយត្រូវថែរក្សារហូតដល់ថ្ងៃបោះឆ្នោត និងចំនួន ១ ច្បាប់ទៀតរក្សាទុកជាឯកសារនៅ គឃ.សប។ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្តនីមួយៗ ត្រូវបានថតចម្លងលើក្រដាស ឬក្នុងស៊ីឌីជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ពាក់ព័ន្ធ ដើម្បីរក្សាទុកជាឯកសារ និងបម្រើដល់សាធារណជន។

មានសំណួរមួយចំនួនបានលើកឡើងដោយភាគីពាក់ព័ន្ធ



សកម្មភាពក្នុងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ

ដែលចូលរួមក្នុងកិច្ចប្រជុំនោះ គឺពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការហែក្បួនឃោសនាបោះឆ្នោត ការដាក់ភ្នាក់ងារគណបក្សនយោបាយ ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការអនុវត្តសេចក្ដីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប ពាក់ព័ន្ធនឹងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត។

តំណាង គ.ជ.ប ដែលបានដឹកនាំកិច្ចប្រជុំនោះ បានឆ្លើយបញ្ជាក់ជូនទៅនឹងការលើកឡើងខាងលើថា ការងាររបស់ គ.ជ.ប មានផែនការមេ មានប្រតិទិននៃការបោះឆ្នោត មានសេចក្ដី-ណែនាំ សេចក្ដីជូនដំណឹងផ្សព្វផ្សាយទៅគ្រប់ភាគីពាក់ព័ន្ធទៅតាមដំណាក់កាលនីមួយៗ ដើម្បីឱ្យភាគីទាំងនោះងាយស្រួលបំពេញការងាររបស់ខ្លួន ជាពិសេសគណបក្សនយោបាយ។ គ.ជ.ប បានអនុវត្តទៅតាមច្បាប់ និងនីតិវិធីនៃការបោះឆ្នោត។ សំណួរខ្លះទៀតពាក់ព័ន្ធនឹងសកម្មភាពការងារនៅពេលខាងមុខ ដូចជាការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត គ.ជ.ប នឹងមានកិច្ចប្រជុំពាក់ព័ន្ធនឹងប្រធានបទទាំងនេះនៅចុង



តំណាងភាគីពាក់ព័ន្ធមានសំណួរក្នុងកិច្ចប្រជុំ

ខែមិថុនា និងក្នុងខែកក្កដា ឆ្នាំ២០២៣ ខាងមុខ ជាបន្តទៀត។ ចំពោះកិច្ចប្រជុំថ្ងៃនេះ គ.ជ.ប ចង់ផ្តោតទៅលើការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ដើម្បីឱ្យគ្រប់ភាគីទាំងអស់បានយល់ និងជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ។ ការងារនេះ គឺដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋ ដែលមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាព ឬមិនទាន់ទទួលបាន ឬបាត់ ឬខូច ឬកែតម្រូវ ឱ្យពួកគាត់ទៅធ្វើ ឯ.អ ទាន់ពេលវេលា ដើម្បីបោះឆ្នោត។ គ.ជ.ប បានបញ្ជាក់ជូនទៀតថា ថ្មីៗនេះ រាជរដ្ឋាភិបាលទើបចេញអនុក្រឹត្យ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបន្តសុពលភាពអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ដែលបានអស់សុពលភាព សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។ ខ្លឹមសារក្នុងអនុក្រឹត្យនោះ មាត្រា ៣ បានចែងថា ត្រូវបានបន្តសុពលភាពអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ដែលបានអស់សុពលភាពប្រើប្រាស់ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ រហូតដល់ថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧។

ក្នុងកិច្ចប្រជុំនោះ មានការអញ្ជើញចូលរួមពីតំណាងក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធ-ហត្ថលើផ្ទៃប្រទេស តំណាងស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា តំណាងគណបក្សនយោបាយ តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ចំនួនប្រមាណ ៧០ នាក់៕

# អ្នកសង្កេតការណ៍ដែលត្រូវសង្កេតមើលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គិតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានសម្រេចទទួលស្គាល់ជាផ្លូវការអ្នកសង្កេតការណ៍ជាតិ សរុបចំនួន ៧៩.៧៨៣ រូប ក្នុងនោះស្ត្រី សរុបចំនួន ៤៨.៥៣៣ រូប មកពី ៩២ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងភ្ញៀវពិសេស សរុបចំនួន ៦ រូប ក្នុងនោះស្ត្រីចំនួន ១ រូប មកពី ៣ ស្ថាប័ន ដើម្បីចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដូចមានក្នុងតារាងខាងក្រោម៖

**១. អ្នកសង្កេតការណ៍ជាតិ**

| ល.រ | សមាគម អង្គការ | រាជធានី ខេត្ត | ស្នើសុំ | | | | បដិសេធ | | អនុញ្ញាត | |
|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | ចល័ត | | សរុប | ស្រី | សរុប | ស្រី |
| | | | | | សរុប | ស្រី | | | | |
| ១ | សហភាពសហព័ន្ធយុវជនកម្ពុជា | ២៥ | ៤០.៦៦៧ | ១៧.៦៣០ | | | ២៨ | ១៩ | ៤០.៦៣៩ | ១៧.៦១១ |
| ២ | គណៈកម្មាធិការដើម្បីការបោះ-ឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) | ២៥ | ៤.០០៤ | ១.៨៦២ | ១០ | ២ | | | ៤.០០៤ | ១.៨៦២ |
| ៣ | អង្គការសហព័ន្ធសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា | ២ | ១៤៧ | ៦៧ | | | | | ១៤៧ | ៦៧ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | ២៥ | ២៥.៣៩៤ | ២៥.៣៩១ | ១០ | ៧ | | | ២៥.៣៩៤ | ២៥.៣៩១ |
| ៥ | អង្គការមេជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព | ១០ | ១៥៥ | ១០៩ | ១០ | ៥ | | | ១៥៥ | ១០៩ |
| ៦ | សមាគមមិត្តយើង | ៦ | ៥៣ | ១៦ | ៦ | ២ | | | ៥៣ | ១៦ |
| ៧ | សមាគមរាជសីហ៍ | ១៩ | ៣២៧ | ៦៥ | ១០ | ៣ | | | ៣២៧ | ៦៥ |
| ៨ | អង្គការដើម្បីអភិវឌ្ឍន៍ និងការពារធនធានធម្មជាតិ | ១៦ | ២២៣ | ២៣ | ១០ | ២ | | | ២២៣ | ២៣ |
| ៩ | សមាគមសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវដើម្បីអប់រំសង្គម | ៤ | ៤ | ៣ | | | | | ៤ | ៣ |
| ១០ | សមាគមសហព័ន្ធនិស្សិត បញ្ញវន្តប្រជាធិបតេយ្យកម្ពុជា | ២៥ | ២.៤១៩ | ១.៤៦៦ | ១០ | | ២២ | ១៥ | ២.៣៩៧ | ១.៤៥១ |
| ១១ | អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា | ១ | ៣ | ១ | | | | | ៣ | ១ |
| ១២ | អង្គការអភិវឌ្ឍន៍កម្ពុជា | ១ | ៥ | ១ | | | | | ៥ | ១ |
| ១៣ | សមាគមជ័យលាភីបញ្ញាជនកម្ពុជា | ៥ | ៤៤ | ៩ | ១០ | ១ | | | ៤៤ | ៩ |
| ១៤ | អង្គការសហគមន៍គ្រួសារ អភិវឌ្ឍន៍កសិកម្ម | ៥ | ២២ | ១៣ | ៨ | ២ | | | ២២ | ១៣ |
| ១៥ | អង្គការអព្យាក្រឹត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរីនៅកម្ពុជា (និកហ្វិច) | ២ | ៤០ | ២៣ | | | | | ៤០ | ២៣ |
| ១៦ | សមាគមយុវជនធ្វើបាន | ១ | ៤ | ២ | | | | | ៤ | ២ |
| ១៧ | សមាគមអរុណរះ | ៥ | ១០ | ៤ | ៣ | ២ | | | ១០ | ៤ |
| ១៨ | អង្គការសហព័ន្ធអង្គការស្ត្រីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | ៥ | ១០ | ៧ | ៥ | ៤ | | | ១០ | ៧ |
| ១៩ | សមាគមសម្ពន្ធយុវជនស្រលាញ់សន្តិភាព | ២ | ១៧៨ | ៦៧ | | | | | ១៧៨ | ៦៧ |
| ២០ | សមាគមបណ្តាញសង្គមស៊ីវិលកម្ពុជា | ៥ | ១១ | ១ | ៥ | | | | ១១ | ១ |
| ២១ | សមាគម សិស្ស និស្សិត បញ្ញវន្តក្មេងវត្ត | ១០ | ៨៥២ | ១៦៧ | | | | | ៨៥២ | ១៦៧ |
| ២២ | អង្គការសហព័ន្ធសន្តិភាពសកល-កម្ពុជា | ១៣ | ៣៤ | ១៣ | | | | | ៣៤ | ១៣ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២៣ | សមាគមសម្ព័ន្ធស្ត្រីខ្មែរ ការពារសិទ្ធិមនុស្ស ដើម្បីអភិវឌ្ឍន៍ | ១ | ៧ | ៥ | | | | | ៧ | ៥ |
| ២៤ | អង្គការកម្មវិធីជួយកុមារអនាថា និងអភិវឌ្ឍន៍ | ២ | ៤ | ២ | | | | | ៤ | ២ |
| ២៥ | អង្គការសេវាប្រជាធិបតេយ្យ | ៦ | ២៦ | ៦ | ៨ | ៣ | | | ២៦ | ៦ |
| ២៦ | សមាគមសហគ្រិនពាណិជ្ជកម្មកម្ពុជា | ៨ | ៣៣ | ១០ | ៤ | | | | ៣៣ | ១០ |
| ២៧ | សមាគមសម្ព័ន្ធយុវជនមូស្លីមកម្ពុជា | ១ | ៤ | ១ | | | | | ៤ | ១ |
| ២៨ | សមាគមនិស្សិតបញ្ញវន្តកម្ពុជា-អាស៊ាន | ១៥ | ៥០ | ៣៨ | ៣ | ១ | | | ៥០ | ៣៨ |
| ២៩ | សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ និងថែរក្សាកុមារកំព្រា ស្ត្រីក្រីក្រ | ៦ | ១៦២ | ៥៩ | ១០ | ៥ | | | ១៦២ | ៥៩ |
| ៣០ | អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា | ១ | ៤ | | | | | | ៤ | |
| ៣១ | អង្គការស្ម័គ្រចិត្តកសាងកម្ពុជា | ១ | ៤ | ៣ | | | | | ៤ | ៣ |
| ៣២ | អង្គការសាលាភាសាបរទេសជុំគៀល | ១ | ៩ | ៥ | | | | | ៩ | ៥ |
| ៣៣ | អង្គការស្តារ និងអភិវឌ្ឍន៍ ជីវភាពគ្រួសារកម្ពុជា | ១ | ៥ | ២ | | | | | ៥ | ២ |
| ៣៤ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចកសិករកម្ពុជា | ១ | ៦ | ១ | | | | | ៦ | ១ |
| ៣៥ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច អតីតយុទ្ធជនកម្ពុជា | ១ | ៨ | ៥ | | | | | ៨ | ៥ |
| ៣៦ | អង្គការសុខភាពផ្លូវចិត្តបែបបុរាណ និងសម័យ | ៥ | ៩ | ១ | | | | | ៩ | ១ |
| ៣៧ | សមាគមសហព័ន្ធវិនិយោគិនកម្ពុជា | ១ | ២៥៩ | ៧១ | | | | | ២៥៩ | ៧១ |
| ៣៨ | អង្គការអភិវឌ្ឍន៍នារីខ្មែរ | ១ | ៤ | ២ | | | | | ៤ | ២ |
| ៣៩ | អង្គការអនាគតកុមារ | ១ | ៥ | ២ | | | | | ៥ | ២ |
| ៤០ | អង្គការព្រហ្មវិហារធម៌ | ១ | ៤ | ២ | | | | | ៤ | ២ |
| ៤១ | អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន | ១ | ៤ | ២ | | | | | ៤ | ២ |
| ៤២ | អង្គការបញ្ញាពលរដ្ឋកម្ពុជា | ៤ | ១៦ | ៧ | | | | | ១៦ | ៧ |
| ៤៣ | សមាគមអភិវឌ្ឍន៍ជនពិការបាត់ | ១ | ៥ | ៥ | | | | | ៥ | ៥ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤៤ | អង្គការសហព័ន្ធអភិវឌ្ឍន៍ជនពិការស្វាយអន្ទរ | ១ | ៥ | ៥ | | | | | ៥ | ៥ |
| ៤៥ | អង្គការសហព័ន្ធនារីពិការ | ១ | ៥ | ៤ | | | | | ៥ | ៤ |
| ៤៦ | អង្គការផ្តល់ក្តីសង្ឃឹម | ១ | ៤ | ២ | | | | | ៤ | ២ |
| ៤៧ | អង្គការភ្ញុំស្រីដើម្បីអភិវឌ្ឍន៍ | ១ | ៤ | ៣ | | | | | ៤ | ៣ |
| ៤៨ | អង្គការសម្ព័ន្ធសន្តិភាពកម្ពុជា | ១ | ៥ | ២ | | | | | ៥ | ២ |
| ៤៩ | សមាគមក្តីសង្ឃឹមរបស់ជនក្រីក្រ | ១ | ៤ | ១ | | | | | ៤ | ១ |
| ៥០ | សមាគមសហព័ន្ធពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា | ១ | ២៥៥ | ៧៧ | | | | | ២៥៥ | ៧៧ |
| ៥១ | សមាគមសហព័ន្ធសិប្បកម្មឧស្សា-ហកម្ម និងថាមពលកម្ពុជា | ១ | ២១៨ | ៦២ | | | | | ២១៨ | ៦២ |
| ៥២ | សមាគមសហព័ន្ធអភិវឌ្ឍន៍ដីធ្លី និងសំណង់កម្ពុជា | ១ | ២៥០ | ៦៦ | | | | | ២៥០ | ៦៦ |
| ៥៣ | សមាគមអ្នកផ្តល់សេវាសុខភាពប្រជាជនកម្ពុជា | ១ | ២១៥ | ៦៥ | | | | | ២១៥ | ៦៥ |
| ៥៤ | សមាគមអាយវីអេហ្សកម្ពុជា | ១ | ២២៤ | ៥១ | | | | | ២២៤ | ៥១ |
| ៥៥ | សមាគមសហព័ន្ធទេសចរណ៍ និងបដិសណ្ឋារកិច្ចកម្ពុជា | ១ | ២៤៩ | ៨១ | | | | | ២៤៩ | ៨១ |
| ៥៦ | សមាគមសហព័ន្ធការពារអ្នកប្រើ-ប្រាស់នៅកម្ពុជា | ១ | ២២៩ | ៥៨ | | | | | ២២៩ | ៥៨ |
| ៥៧ | សមាគមយុវជនសេដ្ឋកិច្ចកម្ពុជា | ១ | ២៥៩ | ៧៥ | | | | | ២៥៩ | ៧៥ |
| ៥៨ | អង្គការវេទិកាអភិវឌ្ឍន៍ស្ត្រី និងកុមារពិការខ្មែរ | ១ | ៤ | ៣ | | | | | ៤ | ៣ |
| ៥៩ | សមាគមស្ត្រីសំរាប់អភិវឌ្ឍន៍សិទ្ធិមនុស្ស ឧស្សាហកម្ម កសិកម្ម | ២ | ១០ | ៦ | | | | | ១០ | ៦ |
| ៦០ | សមាគមសម្ពន្ធភាពអង្គការ-សមាគម និងវិស័យឯកជននៅកម្ពុជា | ១ | ២៧៣ | ៧២ | | | | | ២៧៣ | ៧២ |
| ៦១ | សមាគមសហព័ន្ធធុរកិច្ចទីផ្សារបណ្តាញកម្ពុជា | ១ | ២៥៧ | ៧៤ | | | | | ២៥៧ | ៧៤ |
| ៦២ | សមាគមសហព័ន្ធអាជីវករកម្ពុជា | ១ | ២៣៣ | ៧១ | | | | | ២៣៣ | ៧១ |
| ៦៣ | សមាគមអ្នកលក់ឱសថកម្ពុជា | ១ | ២៣៣ | ៦៨ | | | | | ២៣៣ | ៦៨ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦៤ | សមាគមអ្នកលក់ផ្ទាល់នៅកម្ពុជា | ១ | ២៣១ | ៧៧ | | | | | ២៣១ | ៧៧ |
| ៦៥ | សមាគមសហព័ន្ធវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រកម្ពុជា | ១ | ២៣២ | ៧៥ | | | | | ២៣២ | ៧៥ |
| ៦៦ | សហគមន៍ អភិវឌ្ឍន៍ជាតិ | ១៧ | ២៦៧ | ៤២ | ៥ | ១ | | | ២៦៧ | ៤២ |
| ៦៧ | អង្គការសង្គ្រោះអនាគតកុមារខ្មែរ | ១ | ៥ | ២ | | | | | ៥ | ២ |
| ៦៨ | សមាគមសម្ពន្ធភាពកសិកម្មនិងបរិស្ថានកម្ពុជា | ១ | ២៣១ | ៥៦ | | | | | ២៣១ | ៥៦ |
| ៦៩ | អង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការ | ១ | ៦ | ៤ | | | | | ៦ | ៤ |
| ៧០ | អង្គការអភិវឌ្ឍន៍សុខភាពគ្រួសារ | ១ | ៤ | ២ | | | | | ៤ | ២ |
| ៧១ | អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ | ១ | ៤ | ២ | | | | | ៤ | ២ |
| ៧២ | អង្គការមូលនិធិអភិវឌ្ឍន៍មេគង្គកម្ពុជា | ៣ | ៥ | ១ | | | | | ៥ | ១ |
| ៧៣ | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាននិងសហគ្រិនភាព | ១ | ៤ | ១ | | | | | ៤ | ១ |
| ៧៤ | អង្គការបំប៉នវិជ្ជាជីវៈអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្មជនបទ | ១ | ៧ | ៤ | | | | | ៧ | ៤ |
| ៧៥ | អង្គការវេទិកាស្ត្រី និងកុមារពិការខេត្តកំពត | ១ | ៤ | ២ | | | | | ៤ | ២ |
| ៧៦ | សមាគមសំណាងអភិវឌ្ឍន៍ជនបទ | ១ | ៤ | ៣ | | | | | ៤ | ៣ |
| ៧៧ | អង្គការអភិវឌ្ឍន៍ស្ត្រី | ១ | ៥ | ១ | | | | | ៥ | ១ |
| ៧៨ | សមាគមអភិវឌ្ឍន៍ស្រុកស្រែ | ១ | ៤ | ៤ | | | | | ៤ | ៤ |
| ៧៩ | អង្គការទ្រទ្រង់ស្ត្រីខ្មែរ ខេត្តកំពង់ធំ | ១ | ៤ | ២ | | | | | ៤ | ២ |
| ៨០ | អង្គការក្រុមទ្រទ្រង់ភូមិ | ១ | ៤ | ៣ | | | | | ៤ | ៣ |
| ៨១ | សមាគមអភិវឌ្ឍន៍អតីតអ្នកបំរើជាតិ | ១ | ៧ | ៥ | | | | | ៧ | ៥ |
| ៨២ | សមាគមសហព័ន្ធអភិវឌ្ឍន៍ជនពិការឃុំស្វាយក្រវ៉ាន់ | ១ | ៤ | ១ | | | | | ៤ | ១ |
| ៨៣ | អង្គការសហព័ន្ធអភិវឌ្ឍន៍ជនពិការស្រុកសំរោងទង | ១ | ៤ | ២ | | | | | ៤ | ២ |
| ៨៤ | សមាគមរថយន្តដឹកជញ្ជូនទេសចរណ៍សេកុងត្រពាំងក្រៀល | ១ | ៥ | ១ | | | | | ៥ | ១ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៨៥ | សមាគមសម្ព័ន្ធសារព័ត៌មានឯករាជ្យ | ៣ | ៣៩ | ៩ | | | | | ៣៩ | ៩ |
| ៨៦ | អង្គការមូលនិធិស្ត្រីកម្ពុជា | ១ | ៥ | ១ | | | | | ៥ | ១ |
| ៨៧ | អង្គការការពារបរិស្ថាន និងធនធានធម្មជាតិ | ១ | ៤ | | | | | | ៤ | |
| ៨៨ | អង្គការគណៈកម្មាធិការសម្របសម្រួលកម្ពុជា | ១៥ | ៥៥៥ | ២៤២ | ៩ | ៣ | | | ៥៥៥ | ២៤២ |
| ៨៩ | អង្គការសហគមន៍ព្រះអាទិត្យអភិវឌ្ឍន៍កម្ពុជា | ១ | ៧ | ៣ | | | | | ៧ | ៣ |
| ៩០ | អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម | ១ | ៤ | ២ | | | | | ៤ | ២ |
| ៩១ | អង្គការផ្តល់ក្តីមេត្តានៅកម្ពុជា | ១ | ៣ | ១ | | | | | ៣ | ១ |
| ៩២ | សមាគមសម្ពន្ធប្រជាជនដើម្បីសន្តិភាព | ១ | ៥ | ៤ | | | | | ៥ | ៤ |
| **សរុបរួម** | | | **៧៩.៨៣៣** | **៤៨.៥៦៧** | **១៣៦** | **៤៣** | **៥០** | **៣៤** | **៧៩.៧៨៣** | **៤៨.៥៣៣** |

## ២. ភ្ញៀវពិសេស

| **ល.រ** | **ស្ថាប័ន** | **ស្នើសុំ** | | **បដិសេធ** | | **អនុញ្ញាត** | |
|---|---|---|---|---|---|---|---|
| | | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| ១ | សមាគមកុមារជ័យនៅប្រទេសបារាំង ( KOMAR CHEY ASSOCIATION in France ) | ២ | | | | ២ | |
| ២ | Niigata University of International and Information Studies ( Japan ) | ១ | | | | ១ | |
| ៣ | ស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា | ៣ | ១ | | | ៣ | ១ |
| **សរុបរួម** | | **៦** | **១** | | | **៦** | **១** |

គំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ មានផ្តល់ជូនដោយឥតគិតថ្លៃ ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប ( www.nec.gov.kh/khmer/content/6536 ) និងត្រូវដាក់ពាក្យនៅទីស្តីការ គ.ជ.ប (ការិយាល័យកិច្ចការគណបក្សនយោបាយ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាន់ទី៩ ) រៀងរាល់ម៉ោងធ្វើការ ពេលព្រឹក ពីម៉ោង ៧:០០ ដល់ ១១:៣០នាទី និងពេលរសៀល ពីម៉ោង ១៤:០០ ដល់ ១៧:៣០នាទី។ ការដាក់ និងការទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ ប្រព្រឹត្តទៅពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ និងអ្នកសង្កេតការណ៍អន្តរជាតិ ចាប់ពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣៕

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: គ.ជ.ប

## តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត
## សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ចាប់ពីថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣)

| ល.រ | រាជធានី ខេត្ត | ចំនួនឃុំ សង្កាត់ | ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតសរុប | ចំនួនបណ្ណព័ត៌មានអ្នកបោះឆ្នោតចែកសរុប | គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 67 | 431,775 | 376,243 | 87.14% | |
| 02 | បាត់ដំបង | 103 | 661,970 | 612,026 | 92.46% | |
| 03 | កំពង់ចាម | 109 | 652,540 | 627,099 | 96.10% | |
| 04 | កំពង់ឆ្នាំង | 71 | 359,698 | 348,345 | 96.84% | |
| 05 | កំពង់ស្ពឺ | 88 | 599,245 | 580,824 | 96.93% | |
| 06 | កំពង់ធំ | 81 | 456,705 | 442,145 | 96.81% | |
| 07 | កំពត | 93 | 421,119 | 406,030 | 96.42% | |
| 08 | កណ្ដាល | 127 | 818,459 | 777,755 | 95.03% | |
| 09 | កោះកុង | 29 | 78,301 | 70,328 | 89.82% | |
| 10 | ក្រចេះ | 48 | 231,837 | 219,407 | 94.64% | |
| 11 | មណ្ឌលគិរី | 21 | 51,627 | 46,401 | 89.88% | |
| 12 | ភ្នំពេញ | 105 | 961,742 | 847,307 | 88.10% | |
| 13 | ព្រះវិហារ | 51 | 151,191 | 143,434 | 94.87% | |
| 14 | ព្រៃវែង | 116 | 750,836 | 724,345 | 96.47% | |
| 15 | ពោធិ៍សាត់ | 49 | 300,328 | 281,344 | 93.68% | |
| 16 | រតនគិរី | 50 | 117,657 | 110,698 | 94.09% | |
| 17 | សៀមរាប | 100 | 618,835 | 586,509 | 94.78% | |
| 18 | ព្រះសីហនុ | 29 | 149,807 | 129,630 | 86.53% | |
| 19 | ស្ទឹងត្រែង | 34 | 97,452 | 91,407 | 93.80% | |
| 20 | ស្វាយរៀង | 80 | 415,919 | 401,155 | 96.45% | |
| 21 | តាកែវ | 100 | 668,548 | 653,221 | 97.71% | |
| 22 | កែប | 5 | 28,198 | 26,984 | 95.69% | |
| 23 | ប៉ៃលិន | 8 | 45,740 | 36,956 | 80.80% | |
| 24 | ឧត្តរមានជ័យ | 24 | 151,168 | 134,162 | 88.75% | |
| 25 | ត្បូងឃ្មុំ | 64 | 489,958 | 467,044 | 95.32% | |
| **សរុប** | | 1,652 | 9,710,655 | 9,140,799 | 94.13% | |

ថ្ងៃអង្គារ ១០កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមិថុ ឆ្នាំ២០២៣

# អ.ខ គំរូថ្មី ដែលអស់សុពលភាពប្រើប្រាស់ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ អាចប្រើប្រាស់បានសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧

ដើម្បីអាចបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ បាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ និងមានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ដែលជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)។

បើយោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ដែលអស់សុពលភាពប្រើប្រាស់ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ត្រូវបានបន្តសុពលភាពសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ មានន័យថា ចំពោះអ្នកដែលប្រើប្រាស់ អ.ខ ប្រភេទថ្មី ដែលនៅមានសុពលភាព ឬទើបផុតសុពលភាពក្នុងឆ្នាំ២០២២ ឬឆ្នាំ២០២៣ អាចប្រើសម្រាប់ការបោះឆ្នោតបានដូចគ្នា។

ដោយឡែក ចំពោះប្រជាពលរដ្ឋដែល អ.ខ របស់ខ្លួនបានអស់សុពលភាពមុនឆ្នាំ២០២២ ឬបាត់ ឬខូច ឬកែតម្រូវ ឬមិនទាន់ទទួលបាន អាចទៅស្នើសុំ ឯ.អ ពីគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) និងត្រូវបញ្ជាក់សុពលភាពដោយអាជ្ញាធរឃុំ សង្កាត់ នៃឃុំ សង្កាត់ ដែលខ្លួនត្រូវទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា។

កាលបរិច្ឆេទសម្រាប់ការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតតាមឃុំ សង្កាត់ មានរយៈពេល ៣០ថ្ងៃ គឺចាប់ផ្ដើមពីថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ត្រឹមវេលាម៉ោង ៥:៣០នាទីល្ងាច។ ការស្នើសុំ និងការចេញ ឯ.អ ពុំមានបង់ប្រាក់ឡើយ៕

---

# បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

- ប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត
- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀត
- និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថមាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់
- រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ

- ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្ដិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ
- ផ្ដល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត
- ធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅចន្លោះពីម៉ោង ១០ យប់ ដល់ម៉ោង ៦ ព្រឹក
- ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេងចាប់ពីម៉ោង ១២ ថ្ងៃត្រង់ ដល់ម៉ោង ២ រសៀល
- ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត
- រារាំងដល់សកម្មភាពរបស់ភ្នាក់ងារគណបក្សនយោបាយដទៃទៀត
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយ មិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប
- ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយ ធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត
- បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន
- បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត
- ទិញសន្លឹកឆ្នោត ដោយសម្ភារ ឬដោយប្រាក់កាស
- បង្ខាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត
- ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្ដើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត
- ទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ
- ផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីបោះឆ្នោត
- ជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត
- ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្សពួក ភេទ ឋានៈក្នុងសង្គម សមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ និងតាមគ្រប់រូបភាពទាំងអស់
- រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀត
- ប្រើប្រាស់ភាសា ពាក្យសំដីដែលស្ដែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ
- ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តបណ្ណដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្ដី ឬដោយអាវុធ
- ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សា តាមរយៈសេចក្ដីថ្លែងការណ៍ សេចក្ដីប្រកាសខិត្តបណ្ណ រូបភាពបិទផ្សាយ និងសម្ភារឃោសនាបោះឆ្នោតផ្សេងទៀត
- ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយដែលមានសំឡេងខ្លាំងៗលុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត

- ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង នៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា
- ប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាម ព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា ស្លាកសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសំឡេងឆ្នោត
- ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន
- បិទបណ្ណ ខិត្តបណ្ណ រូបភាពឃោសនា សេចក្តីថ្លែង-ការណ៍នយោបាយ ឬឯកសារឃោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ
- បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយ ខិត្តបណ្ណ សេចក្តីប្រកាស នយោបាយ ឬឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួង ស្ថាប័ននានា ឬអាជ្ញាធរដែនដី
- បិទបណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាបោះឆ្នោតដទៃទៀត ក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ
- ចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈ
- ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ
- ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកសញ្ញារាជការ ឬរដ្ឋ រាជរដ្ឋាភិបាល នគរបាល ឬ ន.ប ខេមរភូមិន្ទ ឬ ខ.ម ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត
- ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត
- ប្រើប្រាស់តួនាទី សិទ្ធិអំណាចបុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ
- ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត
- ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត
- នៅក្បែរបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោត
- ត្រូវជៀសវាងការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយា-ល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ
- មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះ-ឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

# ប្រធាន គ.ជ.ប អំពាវនាវឱ្យប្រជាពលរដ្ឋត្រៀមខ្លួន និងត្រៀមឯកសារ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអំពាវនាវដល់ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២២ ទាំងអស់ ត្រៀមខ្លួន និងត្រៀមឯកសារសម្រាប់ទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ។ ឯកសារដែលអ្នកបោះឆ្នោតត្រូវមាន គឺអត្តសញ្ញាណប័ណ្ណ-សញ្ជាតិខ្មែរ (អ.ខ) ប្រភេទថ្មី ដែលមានសុពលភាព ឬអត្ត-សញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទថ្មី ដែលផុតសុពលភាពនៅឆ្នាំ២០២២ ឬឆ្នាំ២០២៣ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ)។

តាមរយៈសេចក្តីអំពាវនាវ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ នេះ ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានជំរុញឱ្យប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០២២ ដែលបានប្រើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ហើយមិនទាន់មាន អ.ខ ឬ មិនទាន់ទទួលបាន អ.ខ ឬបាត់ ឬខូច ឬកែតម្រូវ សូមប្រញាប់ប្រសាន់ទៅស្នើសុំ ឯ.អ ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងត្រូវបញ្ជាក់សុពលភាពដោយអាជ្ញាធរឃុំ សង្កាត់ នៃឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវទៅបោះឆ្នោតឱ្យបានទាន់ពេលវេលា។ ការចេញ ឯ.អ មានរយៈពេល ៣០ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី២២ ខែមិថុនា និងត្រូវបញ្ចប់ត្រឹមថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៥:៣០នាទីល្ងាច។

ឯកឧត្តម បានបង្ហាញនូវជំនឿយ៉ាងមុតមាំថា គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមេឃុំ ចៅសង្កាត់ នឹងយកចិត្តទុកដាក់ជំរុញ និងពង្រឹងការចេញ ឯ.អ ជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យបានទាន់ពេលវេលា ដើម្បីប្រជា-ពលរដ្ឋប្រើប្រាស់ក្នុងការបោះឆ្នោត។

ជាមួយគ្នានេះដែរ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ គ.ជ.ប ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២២ ហើយកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេស សូមវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមបោះឆ្នោត ដោយមកបោះឆ្នោតនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ខាងមុខនេះ។

ជាមួយគ្នានេះ គ.ជ.ប ក៏បានស្នើសុំកិច្ចសហការពីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដើម្បីជួយផ្សព្វ-ផ្សាយសេចក្តីអំពាវនាវនេះដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេសឱ្យបានទូលំទូលាយ៕




អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ)



ឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការបោះឆ្នោត (ឯ.អ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ : ០០៣ គ.ជ.ប. ស.ព.ន

# សេចក្តីអំពាវនាវ

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) ការឃោសនាបោះឆ្នោត មានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត។ ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។

នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលមានរយៈពេល ២១ថ្ងៃ ចាប់ពីថ្ងៃទី១ ខែកក្កដា រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមអំពាវនាវដល់គណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង ច.ប.ត.រ គោរពតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្រមសីលធម៌ និងគោលការណ៍នានា ដែលបានកំណត់ដោយ គ.ជ.ប ដើម្បីឱ្យការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយប្រព្រឹត្តទៅដោយសន្តិវិធី អហិង្សា សន្តិសុខ និងសុវត្ថិភាព។

គ.ជ.ប សូមអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងក្នុងសកម្មភាពការងាររបស់ខ្លួន និងត្រូវសម្របសម្រួលទីកន្លែង ផ្លូវ ពេលវេលា ដើម្បីឱ្យគណបក្សនយោបាយនីមួយៗ អាចអនុវត្តកម្មវិធីឃោសនាបោះឆ្នោត និងការហែក្បួនឃោសនាបោះឆ្នោតរបស់ខ្លួនប្រព្រឹត្តទៅដោយស្មើភាពគ្នា។

គ.ជ.ប សង្ឃឹមយ៉ាងមុតមាំថា គ្រប់គណបក្សនយោបាយ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធ នឹងចូលរួមសហការតាមការអំពាវនាវក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដោយគោរពច្បាប់ជាធរមាន ដើម្បីឱ្យការឃោសនាបោះឆ្នោតនេះ ប្រព្រឹត្តទៅដោយរលូន និងធានាបាននូវសិទ្ធិរបស់គណបក្សនយោបាយ និងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ថ្ងៃច័ន្ទ ៥ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

គ.ជ.ប

# គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧

## ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣

| | | |
|---|---|---|
| ១ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | គ.ស.ស.ប |
| ២ | គណបក្សខ្មែរតែមួយ | គ.ខ.ម |
| ៣ | គណបក្សសញ្ជាតិកម្ពុជា | គ.ស.ក |
| ៤ | គណបក្សខ្មែររួបរួមជាតិ | ខ.រ.ជ |
| ៥ | គណបក្សកម្លាំងប្រជាធិបតេយ្យ | គ.ក.ប |
| ៦ | គណបក្សកសិករ | គ.ក |
| ៧ | គណបក្សស្ត្រីដើម្បីស្ត្រី | ស.ដ.ស |
| ៨ | គណបក្សខ្មែរឈប់ក្រ | គ.ខ.ឈ.ក |
| ៩ | គណបក្សហ្វ៊ុនស៊ិនប៉ិច | រ.រ.ជ.ក.ឯ.អ.ស.ស |
| ១០ | គណបក្សធម្មាធិបតេយ្យ | គ.ធ |
| ១១ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន | គបម |
| ១២ | គណបក្សបំណងពលរដ្ឋ | គ.ប.ព |
| ១៣ | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | គ.ខ.អ.ស |
| ១៤ | គណបក្សឯកភាពជាតិខ្មែរ | គ.ឯ.ជ |
| ១៥ | គណបក្សខ្មែរអភិវឌ្ឍ | គ.ខ.អ |
| ១៦ | គណបក្សយុវជនកម្ពុជា | គ.យ.ក |
| ១៧ | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | គ.ជ.ប.ក |
| ១៨ | គណបក្សប្រជាជនកម្ពុជា | ប្រ.ជ |

**កំណត់សម្គាល់ ៖ នេះមិនមែនជាសន្លឹកឆ្នោតទេ**

រៀបរៀង និងបោះពុម្ពផ្សាយដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត


ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីមែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News